ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១០៤ MOC / SM 2009

# ប្រកាស
# ស្ដីពី
# នីតិវិធីណែនាំការចុះបញ្ជី និងការការពារ
# ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

- បានឃើញប្រកាសលេខ ២១១ MOC/SM 2007 ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- យោងតាមការចាំបាច់ និងបន្ទាន់ក្នុងការចុះបញ្ជី និងការការពារ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ឈ្មួញខិលខូចមួយចំនួន ប្រើប្រាស់ខុសឆ្គងឈ្មោះទំនិញសម្គាល់ភូមិសាស្ត្រ ធ្វើអោយបាត់បង់កិត្តិសព្ទ ទំនិញសម្គាល់ភូមិសាស្ត្រពិតប្រាកដ

## ស ម្រេ ច

### ប្រការ ១ : គោលដៅ

ប្រកាសនេះមានគោលដៅគ្រប់គ្រង ចុះបញ្ជី ទទួលស្គាល់ និងការពារ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ ២ : គោលបំណង

ប្រកាសនេះ បង្កើតនូវនីតិវិធីស្តីពីការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងការការពារ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងគោលបំណងការពារទ្រព្យសម្បត្តិខាងបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងអ្នកប្រើប្រាស់ផលិតផលម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងរក្សា និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមប្រពៃណី និងអត្តសញ្ញាណជាតិ ដើម្បីបង្កើតការងារនៅជនបទ អភិវឌ្ឍសហគមន៍ កាត់បន្ថយភាពក្រីក្រ និងទាក់ទាញភ្ញៀវទេសចរ ។

### ប្រការ ៣ : វិសាលភាព

ទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម និងទំនិញផ្សេងៗទៀត ដែលផលិត ឬកែច្នៃ ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ អាចត្រូវបានទទួលចុះបញ្ជី និងការពារ ជាម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។


ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

## ប្រការ ៤ : និយមន័យ

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចតទៅ :

១- **"ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ"** សំដៅដល់ឈ្មោះ សញ្ញា សម្គាល់ ឬ រូបភាព ផ្សេងៗទៀត ដែលត្រូវបានប្រើប្រាស់សម្រាប់ជាការហៅ ឈ្មោះ ឬតំណាងអោយប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយ និងអាចកំណត់អត្តសញ្ញាណទំនិញ ថាមានប្រភពដើមក្នុងភូមិសាស្ត្រនោះ ដោយបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិនាម ឬ ចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ។

២-**"ពាក្យស្នើសុំ"** សំដៅដល់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ។

៣-**"អ្នកស្នើសុំ"** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលជាសមាគមសម្គាល់ភូមិសាស្ត្រ ឬ ក្រុមតំណាងផលិតករ ឬ អង្គភាពតំណាងផលិតករ និង ឬ ប្រតិបត្តិករ ដែលអាចមានផលប្រយោជន៍នៅក្នុងការសម្គាល់ភូមិសាស្ត្រទំនិញនោះ ។

៤-**"ប្រតិបត្តិករ"** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលពាក់ព័ន្ធនៅក្នុងដំណើរការប្រមូលទិញ កែច្នៃ ធ្វើពាណិជ្ជកម្ម ឬ ចែកចាយទំនិញការសម្គាល់ភូមិសាស្ត្រទំនិញ ។

៥-**"ព្រឹត្តិបត្រផ្លូវការ"** គឺជាព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាក្រសួងពាណិជ្ជកម្ម ។

៦-**"សៀវភៅបន្ទុក"** សំដៅដល់ឯកសារដែលកំណត់យ៉ាងច្បាស់លាស់ អំពីតំបន់ភូមិសាស្ត្រនៃទំនិញ លក្ខខណ្ឌនៃការផលិត និងដំណើរការត្រួតពិនិត្យគុណភាពទំនិញ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ចេញដោយអ្នកដាក់ពាក្យស្នើសុំ ។

៧-**"ការត្រួតពិនិត្យ"** សំដៅដល់ការផ្ទៀងផ្ទាត់អនុលោមភាពរបស់ទំនិញជាមួយនឹងសៀវភៅបន្ទុក ដោយអង្គភាព ឬ អាជ្ញាធរដែលត្រូវបានចាត់តាំង ។

៨-**"ការចុះបញ្ជី"** សំដៅដល់ការចុះបញ្ជី ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

៩- **“ ថ្ងៃ ”** សំដៅដល់ថ្ងៃនៃប្រតិទិន ។

១០- **“អង្គភាពចេញវិញ្ញាបនបត្រ”** សំដៅដល់អង្គភាពដែលចេញវិញ្ញាបនបត្រ បញ្ជាក់ពីអនុលោមភាពស្របតាមសៀវភៅបន្ទុក ។

## ប្រការ ៥ : សិទ្ធិទទួលបានពីការចុះបញ្ជី

នៅពេលដែលម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញមួយ ត្រូវបានចុះបញ្ជី ការពារនៅ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ស្របតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ផលិតករ និង ឬ ប្រតិបត្តិករដែលអនុវត្តស្របតាមសៀវភៅបន្ទុក ត្រូវបានផ្តល់សិទ្ធិផ្តាច់មុខលើការប្រើប្រាស់ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញនោះ ។ សិទ្ធិនេះ មិនត្រូវបានអនុញ្ញាតឱ្យផ្ទេរឡើយ ។

## ប្រការ ៦ : ភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

ក្រសួងពាណិជ្ជកម្ម ប្រគល់សិទ្ធិគ្រប់គ្រង ចុះបញ្ជី ទទួលស្គាល់ និងការពារម៉ាកសម្រាប់សម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូននាយកដ្ឋានកម្មសិទ្ធិបញ្ញា ។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា មានភារកិច្ចសំខាន់ៗជាអាទិ៍ដូចខាងក្រោម :

- ទទួល និងពិនិត្យពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់សម្គាល់ភូមិសាស្ត្រទំនិញ
- ត្រួតពិនិត្យសៀវភៅបន្ទុក
- ទទួលពាក្យបណ្តឹងជំទាស់ និងបណ្តឹងតប
- ចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ
- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ
- កាន់កាប់បញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ
- បោះពុម្ពផ្សាយម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រឹត្តិប័ត្រផ្លូវការ

## ប្រការ ៧ : ការដាក់ពាក្យស្នើសុំចុះបញ្ជី

១-ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ដូចគំរូក្នុងឧបសម្ព័ន្ធ ១ ភ្ជាប់ ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

២-ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬ ជាភាសាអង់គ្លេស ។ ឯកសារណាមួយដែល ជាផ្នែកនៃពាក្យស្នើសុំ ក្រៅពីភាសាខ្មែរ ឬ ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ។

៣-ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានឯកសារ ដូចខាងក្រោមៈ

ក-ពាក្យស្នើសុំចុះបញ្ជី ចំនួន ០១ ច្បាប់

ខ-សៀវភៅបន្ទុក ចំនួន ០១ ច្បាប់

គ-លិខិតប្រគល់សិទ្ធិ ចេញដោយសមាគមសម្គាល់ភូមិសាស្ត្រ និងមានការបញ្ជាក់ពីមេធាវី ឬសាការី ឬរដ្ឋបាលសារធារណៈស្ថិតនៅក្នុងតំបន់ផលិតការសម្គាល់ភូមិសាស្ត្រទំនិញ

ឃ-និងឯកសារពាក់ពន្ធ័ផ្សេងៗទៀត ដូចមានចែងនៅក្នុងពាក្យស្នើសុំចុះបញ្ជី ។

## ប្រការ ៨ : ការដកពាក្យស្នើសុំចុះបញ្ជី

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខអក្សរ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។

## ប្រការ ៩ : កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាកទំនិញសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

អ្នកស្នើសុំ ចុះបញ្ជីការពារ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ និងកម្រៃរដ្ឋបាលពាក់ពន្ធ័នានា ស្របតាមប្រកាសអន្តរក្រសួង លេខ ៤៥៧ សហវ. ប្រកចមព ចុះថ្ងៃទី ០៨ មិថុនា ឆ្នាំ ២០០៧ ស្តីពី កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ ១០: ការពិនិត្យពាក្យស្នើសុំចុះបញ្ជី

១-នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវរៀបចំដំណើរការពិនិត្យបឋមលើពាក្យស្នើសុំ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

២- នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវផ្ទៀងផ្ទាត់ពាក្យស្នើសុំនោះថាបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ ហើយត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំនោះ ឬ បដិសេធ ជាផ្លូវការ។

៣- លិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់នូវកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ និងលេខដាក់ពាក្យ ។

៤- ការបដិសេធពាក្យស្នើសុំចុះបញ្ជី ត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធ និងជូនដំណឹងទៅអ្នកស្នើសុំ ។ អ្នកស្នើសុំ អាចធ្វើការកែតម្រូវពាក្យស្នើសុំ ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ ។ ពាក្យស្នើសុំចុះបញ្ជីនោះ ត្រូវចាត់ទុក ថាបានបោះបង់ចោល ប្រសិនបើ គ្មានការកែតម្រូវ ឬ ផ្តល់នូវការឆ្លើយតប ឬពន្យល់ ក្នុងរយៈពេលកំណត់ខាងលើ ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចពន្យាររយៈពេលបន្ថែម ០៦ (ប្រាំមួយ) ខែ ទៀត លើការកែតម្រូវពាក្យស្នើសុំ ប្រសិនបើមាន សំណូមពរពីអ្នកស្នើសុំ ។

៥- ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ដូចខាងក្រោមនេះ មិនត្រូវបានចុះបញ្ជីជា ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ឡើយៈ
- ការសម្គាល់ដែលក្លាយជាពាក្យទូទៅ (Generic Term) ។
- ការសម្គាល់ ដែលប៉ះពាល់ដល់ឈ្មោះដំណាំ ឬ ពូជសត្វពាហនៈណាមួយ។

៦- ការចុះបញ្ជី ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការ ។

## ប្រការ ១១ ៖ ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

១- ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ច ក្នុងការកំណត់នូវបទប្បញ្ញត្តិបន្ថែម សម្រាប់ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

២- នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវពិនិត្យមើលពីប្រសិទ្ធិភាពរបស់ អង្គភាពដែលចេញវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាពស្របតាមសៀវភៅបន្ទុក ដែលមានការយល់ព្រមពីក្រសួងពាណិជ្ជកម្ម ។

៣- ក្នុងការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំ នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬ បុគ្គលដែលមានការពាក់ព័ន្ធ ផ្តល់ការពន្យល់ ឬ ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចស្នើសុំមតិពីជំនាញការក្នុងវិស័យពាក់ព័ន្ធ ដើម្បីពិនិត្យពិចារណា និង ធ្វើការសម្រេច ។

៤- ការត្រួតពិនិត្យនូវអនុលោមភាពរបស់ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញជាមួយនឹងសៀវភៅបន្ទុក ត្រូវបានធានា ដោយអាជ្ញាធរសាធារណៈ ដែលមានសមត្ថកិច្ច និងមិនលំអៀង ឬ ដោយអង្គភាពសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ជាផ្លូវការ អនុលោមតាមអង្គការស្តង់ដាអន្តរជាតិ ISO ៦៥ ឬ តាមសេចក្តីណែនាំរបស់អង្គការស្តង់ដាអន្តរជាតិណាមួយ ដែលអាចជំនួស ឬ បំពេញបន្ថែម ឬ ផ្លាស់ប្តូរ ISO ៦៥ និងដោយមានការយល់ព្រមពីក្រសួងពាណិជ្ជកម្ម ។

របាយការណ៍ប្រចាំឆ្នាំ របស់អង្គភាពចេញវិញ្ញាបនប័ត្រពីគុណភាពទំនិញសម្គាល់ភូមិសាស្ត្រ ត្រូវផ្ញើជូននាយកដ្ឋានកម្មសិទ្ធិបញ្ញា មិនអោយហួសថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ដោយរាប់បញ្ចូលនូវបញ្ជីឈ្មោះប្រតិបត្តិករ ផលិតផល បរិមាណ ដែលខ្លួនបាន បញ្ជាក់ទទួលស្គាល់ និងទណ្ឌកម្មធ្ងន់ធ្ងរដែលបានដាក់ ប្រសិនបើមាន ។

៥- អ្នកស្នើសុំ អាចជ្រើសរើសដោយខ្លួនឯងនូវអង្គភាពផ្តល់វិញ្ញាបនបត្របញ្ជាក់ពីគុណភាពទំនិញ។ ការជ្រើសរើសនេះ គឺជាផ្នែកមួយនៅក្នុងពាក្យស្នើសុំ និង ត្រូវពិនិត្យយល់ព្រមដោយ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

៦- ក្នុងករណីមិនបានបំពេញលក្ខខណ្ឌនៅក្នុងសៀវភៅបន្ទុក ដោយផលិតករ ឬ ប្រតិបត្តិករណាមួយ ឬ ច្រើន អង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ពីគុណភាពទំនិញ ការសម្គាល់ភូមិសាស្ត្រទំនិញ ដែលទទួលបន្ទុកត្រួតពិនិត្យគុណភាពទំនិញសម្គាល់ភូមិសាស្ត្រ ត្រូវដាក់ចេញនូវវិធានការ និងទណ្ឌកម្ម



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៨១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

សមស្របណាមួយ ចំពោះផលិតករ ឬ ប្រតិបត្តិករ ណាមួយ ឬ ច្រើននោះ ដូចខាងក្រោម ៖

- ផ្ញើការកត់សម្គាល់កំហុស និងណែនាំ
- ព្រមាន
- បដិសេធមិនទទួលស្គាល់ឡូណាមួយនៃផលិតផល
- មិនទទួលស្គាល់សិទ្ធិនៃការប្រើប្រាស់ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ជាបណ្តោះអាសន្ន
- ហាមឃាត់ជាស្ថាពរការប្រើប្រាស់ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

**ប្រការ ១២ ៖ សុពលភាព និងការចុះបញ្ជីសាជាថ្មី**

សុពលភាព និងការចុះបញ្ជីសាជាថ្មីនៃ ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញត្រូវអនុវត្តតាមមាត្រា ១២ នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធ ។

**ប្រការ ១៣ ៖ ការលុបចោលម៉ាកទំនិញសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ**

ក្រសួងពាណិជ្ជកម្ម មានសិទ្ធិលុបចោល ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានចុះបញ្ជីរួច មុនផុតសុពលភាព ក្នុងករណីដូចខាងក្រោម ៖

- គ្មានការអនុវត្តនីការត្រួតពិនិត្យតាមផែនការ ដែលបានកំណត់នៅក្នុងសៀវភៅបន្ទុក
- អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនបានផ្តល់ឯកសារ ឬព័ត៌មានបន្ថែម ដល់នាយកដ្ឋានកម្មសិទ្ធិបញ្ញា តាមការស្នើសុំ ក្នុងករណីមានការផ្លាស់ប្តូរបែបបទ នីតិវិធី ក្នុងការចុះបញ្ជី ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ។

**ប្រការ ១៤ ៖ នីតិវិធីអនុវត្តផ្សេងៗទៀត និងទោសប្បញ្ញត្តិ**

នីតិវិធីប្តឹងតវ៉ា នីតិវិធីនៃបណ្តឹងជំទាស់ វិធានការបណ្តោះអាសន្ន វិធានការតាមច្រកព្រំដែន ភ្នាក់ងារតំណាង និងទោសប្បញ្ញត្តិដែលទាក់ទងនឹង



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh

ម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ នៃប្រកាសនេះ ត្រូវអនុវត្តតាម បទប្បញ្ញត្តិពាក់ពន្ធ័នានា កំណត់ក្នុងច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

**ប្រការ ១៥ : សុពលភាព**

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចំលងជូន</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ពន្ធ័
- គ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A&B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccab@moc.gov.kh